តើហេតុអ្វី បានជាអ្នកត្រូវបារម្ភ អំពីមេរោគវ៉ុសណាល (West Nile Virus)?

- មេរោគវ៉ុសណាល (West Nile Virus) អាចធ្វើ ឲ្យគ្រួសាររបស់អ្នកឈឺបាន ។
- មេរោគវ៉ុសណាល អាចឆ្លងរាលដាលដោយសារ សត្វមូស ។
- អ្នកឆ្លងមេរោគវ៉ុសណាលដោយសារមូសខាំ ។
- អ្នកអាចឈឺនៅ 3 –15 ថ្ងៃ បន្ទាប់ពីមូសបានខាំអ្នក ។
- មនុស្សដែលឈឺដោយសារមេរោគនេះ អាចមាន អាការដូចជាគ្រុនផ្តាសាយធំ ។ គេអាចមាន :
  - គ្រុន
  - ឈឺក្បាល
  - ឈឺខ្លួនក្រាណ
  - កន្ទួលសាច់
- មនុស្សមួយចំនួនដែលមានមេរោគវ៉ុសណាល អាចឈឺខ្លាំង ហើយអាចស្លាប់ផង ។
- ភាគច្រើននៃមនុស្សដែលឈឺខ្លាំង គឺជាមនុស្សមាន អាយុប្រហែល 50 ឆ្នាំ ឬចាស់ជាង ប៉ុន្តែមនុស្សគ្រប់ៗ រួបត្រូវការដឹងអំពីមូស ទាំងឡាយ ហើយការពារកុំឲ្យវាមកជិតខ្លួន។ ។

លើសិនជាអ្នកមានសំណួរអ្វី
ទូរស័ព្ទទៅគ្រូពេទ្យរបស់អ្នក ឬមន្ទីរពិនិត្យ

Brought to you by:

Santa Clara County
Vector Control District

1580 Berger Drive, San Jose, CA 95112
408-918-4770/800-675-1155
www.sccvector.org

ដើម្បីឲ្យបានជ្រាបការពិតថែមទៀត សូមទៅមើល :

ក្រសួងសុខាភិបាល រដ្ឋកាលីហ្វ័រនញ៉ា
California Department of Health Services
www.westnile.ca.gov

មជ្ឈមណ្ឌលសំរាប់ត្រួតពិនិត្យ និងបង្ការជំងឺ
Centers for Disease Control and Prevention
www.cdc.gov/ncidod/dvbid/westnile/

KHMER VERSION

ចូរប្រយុទ្ធការពារ ដ៏ចំណាត់ក្បួសកំណាច!

ចូរការពារខ្លួនអ្នក និងគ្រួសារ

របស់អ្នក ពីមេរោគ

វ៉ុស្ត ណាល វ៉ីរុស *(West Nile Virus)*

ដើម្បីឲ្យបានជ្រាបពត៌មានថែមទៀត :
www.westnile.ca.gov
1-877-WVN-BIRD ឬ
1-877-968-2473

តើអ្នកអាចធ្វើអ្វី?

ត្រូវជៀសវាងកុំឲ្យមូសខាំ!

មូសតែងខាំនៅពេលព្រឹកព្រលឹម
និងនៅពេលព្រលប់ៗ ។

នៅពីរម៉ោងបន្ទាប់ពីថ្ងៃលិច គឺជាពេលមូសខាំខ្លាំង
ជាងគេបង្អស់ ។

លើអ្នកចេញទៅក្រៅនៅម៉ោង
នេះ ត្រូវស្លៀកខោជើងវែង
និងពាក់អាវដៃវែង ។

ត្រូវប្រើថ្នាំបាញ់កំចាត់មូសមានសារធាតុ ឌីត
(DEET) ផង ដែរ ។
បាញ់ថ្នាំកំចាត់មូសនៅលើស្បែករបស់អ្នក
ដែលមិនបានគ្របបាំងដោយសំលៀកបំពាក់ ។

ថ្នាំបាញ់កំចាត់មូសដែលមានសារធាតុ
ឌីត (DEET)
រក្សាកុំឲ្យមូសខាំអ្នក ។

ត្រូវធ្វើតាមសេចក្តីពន្យល់ណែនាំ
ដោយប្រុងប្រយ័ត្ន ។

ចូររក្សាផ្ទះសំបែងរបស់អ្នកឲ្យបានសុខ!

មូសតែងតែពង និងញាស់ធំឡើង
នៅក្នុងទីដែលមានទឹកដក់ ។

រាប្រើពេលតែ 7 ថ្ងៃប៉ុណ្ណោះ
ដែលពងមូសចាប់ផ្តើមញាស់
ហើយក្លាយជាមូសពេញវ័យ ។

ត្រូវកំចាត់កុំឲ្យមានទីទឹកដក់
នៅជុំវិញផ្ទះរបស់អ្នក ។

ត្រូវចាក់ទឹកចេញពីធុង ពីកង់
ឡានចាស់ៗ ពីថ្មដាំផ្កា និងពី
ប្រដាប់ប្រដាក្មេងលេង ។

ត្រូវធ្លុះទឹកក្នុងចានសំរាប់ឲ្យសត្វស្លឹក
និងឲ្យសត្វស្លាបងូត យ៉ាង
រាល់ពីរបីថ្ងៃម្តង ។

ត្រូវរក្សាសំណាញ់បង្អួច និងទ្វារកុំឲ្យរហែក ។

សំណាញ់ រក្សាកុំឲ្យមូសចូលបាន ។

ចូរប្រាប់មិត្តភ័ក្តិរបស់អ្នក និង អ្នកជិតខាងរបស់អ្នក!

មេរោគវ៉ីរុសណាល ឥឡូវនេះគេ
បានរកឃើញនៅពាសពេញរដ្ឋកាលី-
ហ្វ័រនញ៉ា ។

បក្សីដែលងាប់ គឺជាសញ្ញាថាមាន
មេរោគវ៉ីរុសណាល នៅក្នុង
តំបន់ដែលអ្នករស់នៅ ។

បក្សីដូចជាសត្វក្អែក ចំពួកក្អែកអ‍ើ
និងល្មាចេក ឈឺជាខ្លាំង ហើយអាច
ងាប់ដោយសារវ៉ីរុសណាលវ‍ីរុស ។

អ្នកមិនធ្លុងមេរោគវ‍ីរុសណាល
ដោយសារការប៉ះនឹងសត្វងាប់ទេ ។

ដើម្បីត្រួតពិនិត្យមើលការធ្លុងរាលដាល
នៃវ‍ីរុស រដ្ឋក៏កំពុងតាមដានសត្វងាប់ ។

ដើម្បីរាយការណ៍អំពីសត្វងាប់ សូមចូលមើល
www.westnile.ca.gov
ឬទូរស័ព្ទទៅលេខឥតគិតថ្លៃ
1-877-WNV-BIRD
ឬ 1-877-968-2473 ។